28

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ..............................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

## សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីកតិកាសញ្ញាជាសាកល ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែតុលា ថ្ងៃទីដប់ នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ មានបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីកតិកាសញ្ញាជាសាកល ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** សហការរៀបចំដោយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ IOM ។

### ១. សមាសភាពចូលរួម

សមាសភាពចូលរួមសរុបចំនួន ១៧៤នាក់ (ស្រី ៦០នាក់) ដែលរួមមានតំណាងមកពីក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត វិស័យឯកជន អង្គការសហប្រជាជាតិ និងអង្គការដៃគូជាតិ-អន្តរជាតិពាក់ព័ន្ធជាច្រើន ។

### ២. សាវតាសង្ខេប និងគោលបំណង

តាំងពីដើមមកមិនដែលមានឯកសារណាចែងឲ្យបានជាក់ច្បាស់អំពីទេសន្តរប្រវេសន៍ឡើយ គឺមានតែនៅតាមប្រទេសរៀងៗខ្លួន ដូចនេះបានជាមានការស្នើសុំឲ្យបង្កើតកតិកាសញ្ញានេះឡើង នៅមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ដោយបានការសម្រេចជាឯកច្ឆ័នចំនួន ១៩៣ប្រទេស ។ កតិកាសញ្ញានេះមិនទាន់លេចចេញជារូបរាងនៅឡើយទេ ដូចនេះត្រូវការប្រមូលផ្តុំធាតុចូលពីបណ្តាប្រទេសនីមួយៗ ដោយត្រូវរៀបចំសិក្ខាសាលាថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកលនៅប្រទេសម៉ិចស៊ីកូ ។

សិក្ខាសាលាពីគ្រោះយោបល់ថ្នាក់ជាតិនៅកម្ពុជានៅពេលនេះ នឹងប្រមូលផ្តុំធាតុចូលពីបណ្តាថ្នាក់ដឹកនាំ និងអ្នកជំនាញបច្ចេកទេសពីគ្រប់ក្រសួង ស្ថាប័ន អង្គភាពរបស់រាជរដ្ឋាភិបាល ក៏ដូចជាវិស័យឯកជន និងអង្គការដៃគូជាតិ-អន្តរជាតិ ដើម្បីរាជរដ្ឋាភិបាលកម្ពុជាយកទៅចូលរួមប្រជុំថ្នាក់តំបន់ នៅប្រទេសថៃ និងថ្នាក់សាកលនៅប្រទេសម៉ិចសិកូ ។

### ៣. ដំណើរការកម្មវិធី

អង្គសិក្ខាសាលាបានប្រព្រឹត្តទៅតាមរបៀបវារៈដែលបានដាក់ជូន និងទទួលបានលទ្ធផល ដូចខាងក្រោម៖

#### ក. សុន្ទរកថា និងចំណាប់អារម្មណ៍

ជាបឋម លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានឡើងមានមតិស្វាគមន៍ និងថ្លែងអំណរគុណចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** និងឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំមកពីគ្រប់ក្រសួង

ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងលោក លោកស្រី តំណាងដៃគូជាតិ និងអន្តរជាតិ ។ បន្ទាប់មក លោកជំទាវបានមានប្រសាសន៍ លើកឡើងនូវចំណុចសំខាន់ៗ នៃអង្គសិក្ខាសាលា៖

ការពិភាក្សាពិគ្រោះយោបល់នេះ គឺជាការប្រមូលផ្តុំបញ្ញាញាណពីបណ្តាថ្នាក់ដឹកនាំ និងអ្នកជំនាញបច្ចេកទេសនៃគ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ក៏ដូចជាការចូលរួមពីអង្គការដៃគូជាតិ និងអន្តរជាតិ ដែលមានបទពិសោធន៍ ដើម្បីចែករំលែក និងផ្លាស់ប្តូរយោបល់គ្នារកឲ្យឃើញនូវគន្លឹះដោះស្រាយចំពោះបញ្ហាទេសន្តរប្រវេសន៍ ដែលកំពុងតែក្លាយទៅជាវិបត្តិដ៏ស្មុគស្មាញមួយសម្រាប់ពិភពលោក ។ ហើយកិច្ចពិភាក្សានឹងប្រព្រឹត្តទៅពេញមួយថ្ងៃ ដោយចែកចេញជា ៦សិក្ខាសាលា ដែលនឹងត្រូវផ្លាស់ប្តូរយោបល់ជាអន្តរស្ថាប័ន លើប្រធានបទជាវិស័យខុសៗគ្នាចំនួន ៦ ។ យើងខ្ញុំសង្ឃឹមថា អង្គពិភាក្សានឹងអាចកំណត់បានអំពីប្រភេទនៃបញ្ហាជុំវិញបរិបទទេសន្តរប្រវេសន៍ ជាពិសេសផលប៉ះពាល់លើស្ត្រីនិងកុមារ វិធានការជាដំណោះស្រាយ រាប់ទាំងច្បាប់ គោលនយោបាយ និងការអនុវត្ត ភាពប្រទាក់ក្រឡានៃច្បាប់គោលនយោបាយ និងបទដ្ឋានជាតិ អន្តរជាតិ ភាពប្រឈមក្នុងការអនុវត្ត វិធានការដោះស្រាយជាគន្លឹះ ចំណុចសេសសល់ និងទិសដៅ ដែលកម្ពុជាបាននិងកំពុងត្រៀមអនុវត្ត តួនាទីរបស់ស្ថាប័នរដ្ឋ និងអ្នកពាក់ព័ន្ធទាំងឡាយ ក៏ដូចជាអនុសាសន៍ជាគន្លឹះសម្រាប់ឲ្យប្រទេសនានាដែលជាប្រទេសប្រភព ប្រទេសគោលដៅ និងប្រទេសសំចត អាចរួមគ្នាអនុវត្ត ដើម្បីលើកកម្ពស់សិទ្ធិ សុវត្ថិភាព និងផលប្រយោជន៍ប្រជាពលរដ្ឋ ដែលជាជនទេសន្តរប្រវេសន៍ និងគ្រួសាររបស់ពួកគេ នៅទូទាំងពិភពលោក ។

ជាកិច្ចបន្ត **សម្តេចក្រឡាហោម** បានអញ្ជើញឡើងមានប្រសាសន៍បើកអង្គសិក្ខាសាលា ដូចខាងក្រោម៖

សូមថ្លែងអំណរគុណចំពោះគំនិតផ្តួចផ្តើម ប្រកបដោយកិច្ចសហការល្អ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ IOM ដែលបានធ្វើឲ្យសិក្ខាសាលាថ្នាក់ជាតិអាចប្រព្រឹត្តទៅបាន ។ សូមថ្លែងអំណរគុណចំពោះកិច្ចសហការ និងការគាំទ្រ ពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលបានអញ្ជើញចូលរួមទាំងអស់ ។

កិច្ចពិភាក្សានេះ នឹងជាឱកាសសម្រាប់ការពិភាក្សាគ្នាឲ្យបានល្អិតល្អន់ អំពីធាតុចូលពាក់ព័ន្ធបញ្ហាទេសន្តរប្រវេសន៍ ដែលបានមកពីបទពិសោធន៍ជាក់ស្តែងកំពុងជួបប្រទះ និងអនុវត្ត រួមទាំងការកសាង និងអនុវត្តច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ សកម្មភាព ដែលពាក់ព័ន្ធ នឹងការលើកកម្ពស់សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ជនទេសន្តរប្រវេសន៍ គ្រួសារ និងវិធីសាស្ត្រល្អៗក្នុងការគ្រប់គ្រងស្ថានភាពលំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ដែលបាននិងកំពុងតែក្លាយជាប្រធានបទក្តៅគគុកមួយត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លា ។ ជនទេសន្តរប្រវេសន៍ គឺជា«**មនុស្ស**» ឯ ទេសន្តរប្រវេសន៍ គឺជា«**ឱកាស**» ដែលមនុស្សត្រូវការសម្រាប់ ជាជម្រើសក្នុងការរស់នៅ ។ ប៉ុន្តែបញ្ហាដែលជាកង្វល់ គឺទេសន្តរប្រវេសន៍ ជាសកម្មភាពឆ្លងដែន រដ្ឋបាល និងនយោបាយនៃប្រទេសមួយ ដែលហួសពីដែនសមត្ថកិច្ចគ្រប់គ្រង និងការធានាសុវត្ថិភាពផ្នែកច្បាប់ និងសង្គមរបស់សមត្ថកិច្ច ។

សូមអំពាវនាវដល់តំណាងក្រសួងស្ថាប័នទាំងអស់ ដែលមានវត្តមាននៅទីនេះ សូមផ្តោតការយកចិត្តទុកដាក់ទៅលើបទពិសោធន៍ ដែលពាក់ព័ន្ធផ្ទាល់នឹងក្រសួង ស្ថាប័ន អង្គភាពផ្ទាល់របស់ខ្លួន ដែលបាននិងកំពុងអនុវត្តកន្លងមក ទៅតាមប្រធានបទនីមួយៗ ដោយប្រមូលផ្តុំលើច្បាប់ គោលនយោបាយ បទដ្ឋានដែលពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ ថ្នាក់តំបន់ អន្តរជាតិ បទដ្ឋានគតិយុត្តិ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ដែលជួយទៅដល់ការថែរក្សាសន្តិសុខសុវត្ថិភាពប្រជាពលរដ្ឋ ក្នុងអំឡុងពេលទេសន្តរប្រវេសន៍ ។ លទ្ធផលនៃការពិភាក្សានេះ នឹងលើកយកទៅពិភាក្សា និងដាក់បញ្ចូលនៅក្នុងកិច្ចពិភាក្សាថ្នាក់តំបន់ ដែលនឹងប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកាខាងមុខនេះ មុននឹងលើកយកទៅ ពិភាក្សានៅថ្នាក់ពិភពលោក ។

សូមថ្លែងអំណរគុណ និងជូនពរជាថ្មី និងសូមប្រកាសបើកកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព ចាប់ពីពេលនេះតទៅ ។

**បន្ទាប់មក លោកស្រី Nenette Motus ប្រធានប្រចាំតំបន់នៃអង្គការ IOM ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក បានឡើងបង្ហាញចំណាប់អារម្មណ៍អំពី ទិដ្ឋភាពទូទៅនៃទេសន្តរប្រវេសន៍ក្នុងបរិបទសាកល តំបន់ និងថ្នាក់ជាតិ ៖** អង្គការ IOM មានមោទនភាពចំពោះទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីឆ្នាំ 1992 ។ កម្លាំងពលកម្មកម្ពុជាមាននៅប្រទេសថៃចំនួន ១២ភាគរយ ហើយការធ្វើចំណាកស្រុកបានក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រទូទាំងប្រទេសកម្ពុជា ដូចនេះបញ្ហាប្រឈមចំពោះចំណាកស្រុកគឺជាបញ្ហាដែលតម្រូវឱ្យមានដំណោះស្រាយគ្រប់ជ្រុងជ្រោយ ដើម្បីធានាឲ្យជនចំណាកស្រុកទទួលបានអត្ថប្រយោជន៍ពេញលេញ ។ នៅខែកញ្ញា ឆ្នាំ២០១៦ មេដឹកនាំពិភពលោកបានប្រមូលផ្តុំគ្នានៅមហាសន្និបាតសេចក្តីថ្លែងការណ៍ក្រុងញូវយ៉ក សម្រាប់កិច្ចពិភាក្សាអំពីបញ្ហាជនភៀសខ្លួន និងពលករចំណាកស្រុក រួមទាំងការប្តេជ្ញាចិត្តសម្រាប់កតិកាសញ្ញាជាសាកលនេះ ដែលនឹងត្រូវបានអនុម័តនៅខែកញ្ញាឆ្នាំ២០១៨ ។ ហើយលទ្ធផលនៃការពិគ្រោះយោបល់នាពេលនេះនឹងរួមចំណែកដល់កិច្ចប្រជុំតំបន់សម្រាប់អាស៊ីប៉ាស៊ីហ្វិក ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងបាងកក ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៧ រៀបចំដោយ ESCAP ដូច្នេះវាមានសារៈសំខាន់ណាស់ ដែលប្រទេសនានាដូចជាប្រទេសកម្ពុជា បានរួមចំណែកផ្តល់នូវបទពិសោធន៍ ជំនាញ និងអនុវត្តល្អៗ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍកតិកាសញ្ញាជាសាកលនេះ ។ IOM កំពុងគាំទ្រដល់ការពិគ្រោះយោបល់ទូទាំងពិភពលោកថ្នាក់តំបន់និងថ្នាក់ជាតិរួមទាំងការពិគ្រោះយោបល់ក្នុងតំបន់នាពេលខាងមុខដោយធ្វើការជាមួយអង្គការ ESCAP និងភ្នាក់ងារអង្គការសហប្រជាជាតិផ្សេងៗទៀត ។ ឯកឧត្តមលោកជំទាវអស់លោកលោកស្រីមានតួនាទីសំខាន់ក្នុងការធានាថាគោលការណ៍ដែលបានដាក់បញ្ចូលក្នុងកតិកាសញ្ញាជាសាកលនេះ ឆ្លុះបញ្ចាំងពីគុណតម្លៃជាសាកលដែលនឹងផ្តល់ប្រយោជន៍ដល់ជនចំណាកស្រុកទាំងអស់ និងជាជំហានដ៏សំខាន់ ដើម្បីធានាថាគោលការណ៍ទាំងនេះត្រូវបានអនុវត្ត ចំពោះជនអន្តោប្រវេសន៍កម្ពុជា និងក្រុមគ្រួសារ ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីការធ្វើចំណាកស្រុក ។

**លោកស្រី Claire Van der Vaeren តំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា បានឡើងបង្ហាញចំណាប់អារម្មណ៍៖** យើងមានកិត្តិយសណាស់បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីកតិកាសញ្ញាជាសាកលស្តីពីការធ្វើចំណាកស្រុកនៅកម្ពុជា។ ការរៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិនេះគឺទាន់ពេលវេលាសម្រាប់ប្រទេសកម្ពុជានៅពេលដែលតំបន់នេះត្រូវបានផ្លាស់ប្តូរកាន់តែខ្លាំងឡើងដោយការបម្លាស់ទីប្រជាជន ។ ក្នុងរយៈពេល១៥ឆ្នាំចុងក្រោយនេះការធ្វើចំណាកស្រុកក្នុងស្រុក និងឆ្លងកាត់ព្រំដែន គឺជាការផ្លាស់ប្តូរដ៏សំខាន់បំផុតមួយនៅក្នុងសង្គមកម្ពុជា ហើយនិន្នាការនេះត្រូវបានព្យាករណ៍ថានឹងបន្ត។ គោលបំណងដើម្បីសម្រួលដល់ការធ្វើចំណាកស្រុកដែលមានសុវត្ថិភាព និងតម្រង់ទិសជាប្រចាំ តម្រូវឲ្យមានអភិបាលកិច្ចផ្នែកចំណាកស្រុកប្រសើរឡើងនៅថ្នាក់ជាតិ និងអន្តរជាតិ ។ ដើម្បីឱ្យមានប្រសិទ្ធភាពដំណើរការបង្រួបបង្រួមទូទាំងពិភពលោកសម្រាប់ដំណើរការធ្វើចំណាកស្រុក គឺទាមទារភាពជាដៃគូដ៏រឹងមាំរវាងរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន និងជនអន្តោប្រវេសន៍ទាំងបុរសនិងស្ត្រី ។ សេចក្តីប្រកាសនៅញូវយ៉កបានសង្កត់ធ្ងន់ថាការធ្វើចំណាកស្រុកអាចផ្តល់នូវការរួមចំណែកច្រើនដល់សង្គមផ្ទះនិងម្ចាស់ផ្ទះ។ ដូចនេះយើងបានប្តេជ្ញាខ្លួនយើងនៅក្នុងសេចក្តីប្រកាសនៅទីក្រុងញូវយ៉កដើម្បីធ្វើការរួមគ្នា និងក្នុងសាមគ្គីភាពឆ្ពោះទៅរកការបង្កើតកតិកាសញ្ញាជាសាកលសម្រាប់ការធ្វើចំណាកស្រុកនៅឆ្នាំ២០១៨ ដែលនឹងធ្វើឲ្យមានការប្តេជ្ញាចិត្តក្នុងការការពារជនអន្តោប្រវេសន៍ ជួយសម្របសម្រួលផ្លូវច្បាប់ និងជួយដល់ជនអន្តោប្រវេសន៍ក្នុងស្ថានភាពងាយរងគ្រោះ។ ចុងបញ្ចប់ សូមទទួលស្គាល់នូវឱកាសដែលបង្កើតឡើងដោយអង្គការ

ទេសន្តរប្រវេសន៍អន្តរជាតិ IOM នៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ ជាមួយនឹងបទពិសោធន៍ជាច្រើនទសវត្ស និងបុគ្គលិកចំនួន១ម៉ឺននាក់នៅទូទាំងពិភពលោក ដោយក្រុមការងារបាននាំមកនូវបទពិសោធន៍ក្នុងវិស័យគ្មានជំនាញ និងបទពិសោធន៍លើការធ្វើចំណាកស្រុក ។ សេចក្តីប្រកាសក្រុងញូវយ៉កបានផ្លាស់ប្តូររបៀបវារៈជាសាកល ដើម្បីធ្វើឲ្យការធ្វើចំណាកស្រុកក្លាយជាអាទិភាពចម្បង ហើយអង្គការសហប្រជាជាតិកំពុងត្រៀមខ្លួនប្រឈមនឹងបញ្ហាប្រឈមនេះ ។

## ខ. កិច្ចពិភាក្សាពិគ្រោះយល់

លោកវេជ្ជបណ្ឌិត Leul Mekonnen ប្រធានបេសកកម្មអង្គការ IOM ប្រចាំកម្ពុជា បានឡើងណែនាំអំពីការបែងចែកក្រុមពិភាក្សាតាមវិស័យទាំង ៦ ។

បន្ទាប់មក អង្គសិក្ខាសាលាបានបែងចែកជាក្រុមពិភាក្សាចំនួន ៦ ដោយមានសមាសភាពបានចូលរួមតាមក្រុមជំនាញរៀងៗខ្លួន ហើយបានធ្វើការពិភាក្សាពិគ្រោះទៅតាម "កម្រងសំនួរ" ដែលបានរៀបចំជូនជាស្រេច ដូចខាងក្រោម៖

**<u>វិស័យទាំង ៦ ដែលត្រូវពិភាក្សាពិគ្រោះយោបល់៖</u>**

**វិស័យទី ១៖** សិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍ ជាពិសេស ស្ត្រី និងកុមារ បរិយាប័ន្នសង្គម ទាក់ទងនឹងគ្រប់ទម្រង់នៃការរើសអើង រួមទាំងការប្រកាន់ពូជសាសន៍ ការមិនអត់អោន ការបែងចែកជនទេសន្តរប្រវេសន៍ និងជនដទៃ ។ល។

**វិស័យទី ២៖** ការឆ្លើយតបទៅនឹងកត្តាដែលនាំឲ្យមានទេសន្តរប្រវេសន៍ ដែលរាប់ទាំងកត្តាប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ កត្តាដែលបង្កដោយមនុស្ស ក្នុងនោះមាន ការបង្ការទប់ស្កាត់ កិច្ចការពារ ការផ្តល់ជំនួយសង្គ្រោះ ការដោះស្រាយវិបត្តិ វិធានការលុបបំបាត់ភាពក្រីក្រ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ល។

**វិស័យទី ៣៖** កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគ្រប់គ្រងទេសន្តរប្រវេសន៍ ក្នុងគ្រប់ទិដ្ឋភាព រួមមាន ការធ្វើអភិបាលកិច្ចព្រំដែន ទាំងពេលឆ្លងកាត់ចេញចូលរបស់ពលករ ការទទួល និងការផ្តល់សេវាព័ត៌មានដល់ពលករ នៅពេលវិលត្រឡប់ ការបញ្ជូន ត្រឡប់ ការធ្វើសមាហរណកម្មទៅសហគមន៍ ឬការត្រឡប់ចេញទៅធ្វើទេសន្តរប្រវេសន៍ជាថ្មី ។ល។

**វិស័យទី ៤៖** ការរួមចំណែករបស់ជនទេសន្តរប្រវេសន៍ ដល់ការអភិវឌ្ឍន៍គ្រប់វិស័យប្រកបដោយចីរភាព ដែលរាប់ទាំងប្រាក់បញ្ញើ ចំណេះដឹងជំនាញបច្ចេកទេស គំនិតផ្តួចផ្តើមថ្មីក្នុងការពង្រីកសក្តានុពលសេដ្ឋកិច្ច ការទទួលបានរបបសន្តិសុខសង្គម ។ល។

**វិស័យទី ៥៖** ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើរត់ពន្ធជនទេសន្តរប្រវេសន៍ និងទម្រង់នៃទាសភាពសម័យថ្មី រួមទាំង វិស័យច្បាប់ ការបង្ការទប់ស្កាត់ កិច្ចការពារ ការកំណត់អត្តសញ្ញាណ ការផ្តល់ជំនួយផ្នែកច្បាប់ និងសេវាគាំទ្រជនរងគ្រោះ ក្នុងអំឡុងពេលទេសន្តរប្រវេសន៍ ។ល។

**វិស័យទី ៦៖** វិធានការចំពោះទេសន្តរប្រវេសន៍មិនប្រក្រតី និងដំណើរការឲ្យមានប្រក្រតីភាព និងភាពស្របច្បាប់នៃទេសន្តរប្រវេសន៍ ការងារសមរម្យ ភាពចល័ត ឬការផ្លាស់ប្តូរ ការងារ ការទទួលស្គាល់ជំនាញ និងគុណវុឌ្ឍន៍ និងវិធានការពាក់ព័ន្ធដទៃទៀត ។

## កម្រងសំនួរសម្រាប់កិច្ចពិភាក្សាពិគ្រោះយោបល់៖

១. តើបញ្ហាអ្វីខ្លះពាក់ព័ន្ធនឹងទេសន្តរ ប្រវេសន៍ ដែលចាំបាច់ត្រូវដោះស្រាយនៅក្នុងវិស័យដែលអ្នកបាន និងកំពុងពិភាក្សា? តើបញ្ហាទាំងនេះពាក់ព័ន្ធដូចម្តេចជាមួយកម្ពុជា ឬតំបន់? តើបញ្ហាណាខ្លះដែលជាអាទិភាពត្រូវលើកមកពិភាក្សា (៣ចំណុច)?

២. តើមានវិធានការអ្វីខ្លះ ដែលរាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានដោះស្រាយកន្លងមក រាប់ទាំងច្បាប់ គោលនយោបាយ យន្តការ និងការអនុវត្ត?

៣. តើច្បាប់ គោលនយោបាយ និងបទដ្ឋានជាតិ អន្តរជាតិពាក់ព័ន្ធទាំងនោះមានភាពប្រទាក់ក្រឡាគ្នាដូចម្តេច?

៤. តើមានភាពប្រឈមអ្វីខ្លះក្នុងការអនុវត្តច្បាប់ ឬគោលនយោបាយទាំងនេះ?

៥. តើព្រះរាជាណាចក្រកម្ពុជាមានទិសដៅគ្រោងនឹងអនុវត្តក្នុងរយៈពេល ២ឆ្នាំ ៥ឆ្នាំ និង១០ឆ្នាំ ខាងមុខដូចម្តេចខ្លះ?(ពិភាក្សាលើផែន ការដែលមានស្រាប់របស់រាជរដ្ឋាភិបាលឬតាមបណ្តាក្រសួងស្ថាប័ន)

៦. តើក្រសួង ស្ថាប័ន ទីភ្នាក់ងារ ឬអង្គភាពពាក់ព័ន្ធរបស់រដ្ឋណាខ្លះ ដែលកំពុងធ្វើការងារលើបញ្ហាទាំងនេះ?

៧. តើតួអង្គអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាលសំខាន់ៗណាខ្លះ (មានដូចជាអង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន គ្រឹះស្ថានអប់រំដែលអាចជាដៃគូជាដើម) សហប្រតិបត្តិការគ្នា ដើម្បីធ្វើការងារឆ្ពោះទៅរកគោលដៅនានាសម្រាប់បញ្ហានេះ?

៨. តើមានអនុសាសន៍អ្វីខ្លះ សម្រាប់ប្រទេសនានា ដែលជាប្រទេសប្រភព ប្រទេសគោលដៅ និងប្រទេសសំចត អាចរួមគ្នាអនុវត្ត ដើម្បីលើកកម្ពស់សិទ្ធិ សុវត្ថិភាព និងផលប្រយោជន៍ប្រជាពលរដ្ឋ ដែលជាជនទេសន្តរប្រវេសន៍ និងគ្រួសាររបស់ពួកគេនៅទូទាំងពិភពលោក?

**(លទ្ធផលនៃកិច្ចពិភាក្សាពិគ្រោះយោបល់ និងបញ្ជីរាយនាមសមាសភាពចូលរួមតាមក្រុមវិស័យ មានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធ)**

អង្គសិក្ខាសាលាបានបញ្ចប់ដោយជោគជ័យ នៅវេលាម៉ោងដប់ប្រាំពីរល្ងាចថ្ងៃខែឆ្នាំដដែល ដោយទទួលបានលទ្ធផលល្អគួរឲ្យកត់សម្គាល់ ។

ភ្នំពេញ ថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ២០១៧
**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ទោ. **ហ៊ី រតនៈ**

គោរពជូន លោកជំទាវ
អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។
ភ្នំពេញ ថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ២០១៧
**ប្រធានលេខាធិការដ្ឋាន**

**ឧត្តមសេនីយ៍ទោ. គង់_ពុទ្ធី**

01/12/17

**ជូ_ប៊ុនអេង**

# បញ្ជីរាយនាមសមាសភាពចូលរួមតាមក្រុមពិភាក្សាពិគ្រោះយោបល់

## ក្រុមពិភាក្សាវិស័យទី១ ៖ សិទ្ធិរបស់ជនទេសន្តប្រវេសន៍

| | | | | |
|---|---|---|---|---|
| ១ | សាន្ត អរុណ | ស្រី | រដ្ឋលេខាធិការ | ក្រសួងកិច្ចការនារី |
| ២ | ប៉ុក បញ្ញាវិចិត្រ | ស្រី | នាយិកាប្រតិបត្តិ | CWCC |
| ៣ | ប៉ែន វិកស៊ី | ស្រី | អនុរដ្ឋលេខាធិការ | ក្រសួងសុខាភិបាល |
| ៤ | ម៉ី ចនថាវី | ស្រី | អគ្គបញ្ជាការរង | ក្រសួងការពារជាតិ |
| ៥ | ហ៊ាង ឆវី | ស្រី | មេបញ្ជាការរង | កងរាជអាវុធហត្ថផ្ទៃប្រទេស |
| ៦ | ឈុន វ៉ារុធ | ស្រី | អភិបាលរងខេត្ត | ខេត្តកោះកុង |
| ៧ | ប៉ុណ្ណ សំខាន់ | ស្រី | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៨ | ហុង សុវណ្ណសុនិតា | ស្រី | មន្ត្រី | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៩ | អ៊ូ ម៉ានីវ៉ា | ប្រុស | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ១០ | ជាតិ ជាលី | ប្រុស | | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា |
| ១១ | កេង ម៉េងឡាង | ប្រុស | | IOM |
| ១២ | ជីន ចន | ប្រុស | អនុប្រធាននាយកដ្ឋាន | ក្រសួងកិច្ចការនារី |
| ១៣ | គុណ វាសនា | ប្រុស | អនុប្រធាន | ក្រុមប្រឹក្សានីតិកម្ម |

## ក្រុមពិភាក្សាវិស័យទី២ ៖ បំរែបំរួលអាកាសធាតុ និងគ្រោះធម្មជាតិ

| | | | | |
|---|---|---|---|---|
| ១ | Kong Kantara | | អនុរដ្ឋលេខាធិការ | ក្រសួងវប្បធម៌ |
| ២ | Un Phally | | | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៣ | Chheang Chanthou | | | ក្រសួងអប់រំ យុវជន និងកីឡា |
| ៤ | Tit Viriya | | | MOF/NIS |
| ៥ | Uch Leang | | | RAC |
| ៦ | Vorn Veth | | | ILO |
| ៧ | Seang Meng | | | WI |
| ៨ | Srey Thol | | | ក្រសួងអប់រំ យុវជន និងកីឡា |
| ៩ | Chet Pisey | | Translater | |
| ១០ | Jun Fujihara | | | UN-Habitat |
| ១១ | Uy Sam Ath | | | Cambodia Red Cross |
| ១២ | Chea Pranimi | | | NCDM |
| ១៣ | Or Vandyma | | | MIH |
| ១៤ | Tep Rany | | | MIH |

| | | | | |
|---|---|---|---|---|
| ១៥ | Prum Sophy | | | MOE |
| ១៦ | Stong Kia | | | MAFF |
| ១៧ | Khlok Vichet Ratha | | | MOE |
| ១៨ | Sakhoeurn Savady | | | MOWA |
| ១៩ | Hor Malin | | | MAFF |
| ២០ | Dum Chanthida | | | IOM |

## ក្រុមពិភាក្សាវិស័យទី៣ ៖ ការគ្រប់គ្រងតាមព្រំដែន

| | | | | |
|---|---|---|---|---|
| ១ | ហ៊ូ សាគុណ | ប្រុស | អគ្គស្នងការរង | អគ្គស្នងការដ្ឋាននគរបាលជាតិ |
| ២ | ថាច់ កេត | ប្រុស | អនុរដ្ឋលេខាធិការ | ក្រសួងព័ត៌មាន |
| ៣ | ញឹម សំបួន | ប្រុស | នាយករង | ទីចាត់ការការងារព្រំដែន |
| ៤ | សេក រតនា | ស្រី | ប្រធានគម្រោង | ចាប់ដៃ |
| ៥ | ឃិន សុភក្តី | ស្រី | ប្រធានគម្រោង | Friends International |
| ៦ | លី ស៊ុនលីណា | ស្រី | អ្នកសម្របសម្រួល | AAPTIP |
| ៧ | ធយ គីមហ៊ង | ស្រី | | |
| ៨ | រ៉ែន សិរីលក្ខិណា | ស្រី | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៩ | Brett Dickson | ប្រុស | PM | IOM |
| ១០ | Phiev Khag | ប្រុស | PO | IOM |
| ១១ | គង់ ពុទ្ធី | ប្រុស | ប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| ១២ | អ៊ុច សុវណ្ណវាសនា | ប្រុស | អនុប្រធានរដ្ឋបាល | ខេត្តកណ្តាល |
| ១៣ | ស៊ិន សូផានី | ប្រុស | មេបញ្ជាការរង | កងរាជអាវុធហត្ថផ្ទៃប្រទេស |
| ១៤ | សោម វណ្ណេត | ប្រុស | នាយរងការិយាល័យ | កងរាជអាវុធហត្ថផ្ទៃប្រទេស |
| ១៥ | ខៀវ ចាន់រ៉ា | ប្រុស | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ១៦ | ម៉ៅ វណ្ណៈ | ប្រុស | អនុប្រធាននាយកដ្ឋាន | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៧ | លី ជាបលី | ប្រុស | នាយការិយាល័យ | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៨ | អ៊ឹង វណ្ណថា | ប្រុស | ប្រធាននាយកដ្ឋាន | ក្រសួងការបរទេស |
| ១៩ | ឆាយ ប៊ុណ្ណា | ប្រុស | ប្រធាននាយកដ្ឋាន | អគ្គនាយកដ្ឋានអន្តោប្រវេសន៍ |

## ក្រុមពិភាក្សាវិស័យទី៤ ៖ ប្រាក់បញ្ញើ និងការអភិវឌ្ឍ

| | | | | |
|---|---|---|---|---|
| ១ | Charle Vann | | Alternate Chairman | សមាគមធនាគារនៅកម្ពុជា |
| ២ | ទេព បូរ៉ាមីន | | | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៣ | សួស ឧសភា | | | ACLEDA Bank |

| | | | | |
|---|---|---|---|---|
| ៤ | គក បូរ៉េន | | | ANZ Royal Bank |
| ៥ | សុទ្ធី សូរិទ្ធីយ៉ា | | | Wing |
| ៦ | ទេព រ៉ូដា | | | ក្រសួងប្រៃសណីយ៍ |
| ៧ | ដារ៉ លក្ខកក្តី | | | ABA Bank |
| ៨ | លឹម ស៊ីហេុង | | | The Asia Foundation |
| ៩ | ភក្តី សម្បូរណ៌ | | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១០ | ហាប់ ស៊ីចាន់ | | | ធនាគារជាតិកម្ពុជា |
| ១១ | មុត មូរីដានី | | | ធនាគារជាតិកម្ពុជា |
| ១២ | កែវ ចរិយា | | | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១៣ | ទូន ផល្លា | | | True Money |
| ១៤ | ធន ឆាយពិសិដ្ឋ | | | RAC |
| ១៥ | អ៊ុច សុវណ្ណា | | | IOM Interpreter |

**ក្រុមពិភាក្សាវិស័យទី៥ ៖ អំពើជួញដូរមនុស្ស និងទម្រង់នៃទាសភាពបែបទំនើប**

| | | | | |
|---|---|---|---|---|
| ១ | Hang Sayorn | ប្រុស | Project officer | CSCW |
| ២ | Lay Vuthy | ប្រុស | អគ្គនាយក | MPTC |
| ៣ | Dy Ryda | ប្រុស | ប្រធានការិយាល័យ | ក្រសួងយុត្តិធម៌ |
| ៤ | Pok Nady | ស្រី | អភិបាលរងខេត្ត | ខេត្តបន្ទាយមានជ័យ |
| ៥ | Keo Maly | ស្រី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| ៦ | Chhay Kimhorn | ស្រី | អនុប្រធាននាយកដ្ឋានកណ្តាល | ក្រសួងមហាផ្ទៃ |
| ៧ | Ly Cheably | ប្រុស | នាយការិយាល័យ | ក្រសួងមហាផ្ទៃ |
| ៨ | លី តុងហ៊ុយ | ប្រុស | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៩ | សួន សុភា | ប្រុស | មន្ត្រីស្រាវជ្រាវ | RAC |
| ១០ | តែ សុថារេត | ប្រុស | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ១១ | សេក សារឿន | ប្រុស | មេធាវី | IJM |
| ១២ | នោ បណ្ឌុល | ប្រុស | មន្ត្រី | ក្រសួងសង្គមកិច្ច |
| ១៣ | សុខ សារិន | ប្រុស | ស្នងការរងយុត្តិធម៌ | កងរាជអាវុធហត្ថផ្ទៃប្រទេស |
| ១៤ | Chhay Bunna | ប្រុស | director | IMM |
| ១៥ | សុខ រឿន | ប្រុស | អគ្គនាយករង | សាលាឧទ្ធរណ៍ |
| ១៦ | កែប សារឿន | ប្រុស | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ១៧ | Nhek Sukum | ស្រី | អភិបាលរងខេត្ត | ខេត្តបាត់ដំបង |
| ១៨ | Ek Sovannphearak | ស្រី | អភិបាលរងខេត្ត | ខេត្តឧត្តរមានជ័យ |

| | | | | |
|---|---|---|---|---|
| ១៩ | Mao Vannak | ប្រុស | អនុប្រធាននាយកដ្ឋាន | ក្រសួងមហាផ្ទៃ |
| ២០ | Suon Sorphea | ស្រី | Coordinator | Ratanak International |
| ២១ | Chhan Sokunthea | ស្រី | Head of section | ADHOC |
| ២២ | Sam Sokey | ស្រី | Social worker | ChabDai |
| ២៣ | Srey Cheum | ប្រុស | មន្ត្រី | ក្រសួងសង្គមកិច្ច |

**ក្រុមពិភាក្សាវិស័យទី៦ ៖ ភាពចល័តនៃការងារ**

| | | | | |
|---|---|---|---|---|
| ១ | សឹុង សរសុចិត្តា | ស្រី | រដ្ឋលេខាធិការ | ក្រសួងការងារ |
| ២ | ឱុច ដាណា | ស្រី | អគ្គនាយករង | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៣ | ហេង សុជាតិ | ប្រុស | Program Manager | UN Women |
| ៤ | រស់ រ៉ា | ប្រុស | Program Manager | SDC |
| ៥ | ស៊ុន រ៉ូ | ប្រុស | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៦ | កែវ ផល្លា | ប្រុស | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៧ | តូច គីមហៀក | ប្រុស | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៨ | សុខ សុគន្ធា | ប្រុស | អ្នកគ្រប់គ្រងផ្នែកទំនាក់ទំនង | Winrock |
| ៩ | Tony Posnett | ប្រុស | Field office Director | Rattanak International |
| ១០ | Moeun Tola | ប្រុស | ED | CENTRAL |
| ១១ | Sem Chansok | ប្រុស | Monitor | LICADHO |
| ១២ | ហោ កុសល | ប្រុស | មន្ត្រី | PLAN |
| ១៣ | សូ វ៉ាន់ឌី | ប្រុស | អនុប្រធាននាយកដ្ឋាន | ក្រសួងមហាផ្ទៃ |
| ១៤ | អៀង សុវិចិត្រ | ប្រុស | Project officer | LSCW |
| ១៥ | ស្រី សាមឌី | ប្រុស | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ១៦ | អោក ភារិន | ប្រុស | អនុប្រធានការិយាល័យ | គ.ជ.ប.ជ |
| ១៧ | ប៉ូច វរលក្ខណ៍ | ស្រី | ប្រធាននាយកដ្ឋាន | MOT |
| ១៨ | នូ សុផល | ប្រុស | អគ្គាធិការរង | MOT |
| ១៩ | យ៉េង វីរៈម៉ារី | ស្រី | មន្ត្រីសម្របសម្រួល | ACPIS |

## ទិស័យទី១ ៖ សិទ្ធិរបស់ជនទេសន្តប្រវេសន៍

សិទ្ធិមនុស្សរបស់ជនទេសន្តប្រវេសន៍ ជាពិសេស ស្ត្រី និងកុមារ បរិយាប័ន្នសង្គម ទាក់ទងនឹងគ្រប់ទម្រង់នៃការរើសអើង រួមទាំងការប្រកាន់ពូជសាសន៍ ការមិនអត់អោន ការបែងចែកជនទេសន្តប្រវេសន៍ និងជនដទៃ ។ល។

| | | |
|---|---|---|
| ១. តើបញ្ហាអ្វីខ្លះពាក់ព័ន្ធនឹងទេសន្តប្រវេសន៍ ដែលចាំបាច់ត្រូវដោះស្រាយនៅក្នុងវិស័យដែលអ្នកបាន និងកំពុងពិភាក្សា? តើបញ្ហាទាំងនេះពាក់ព័ន្ធដូចម្តេចជាមួយកម្ពុជា ឬតំបន់? តើបញ្ហាណាខ្លះដែលជាអាទិភាពត្រូវលើកមកពិភាក្សា (៣ចំណុច)? | ១- មិនបានទទួលសេវាសង្គម៖<br>ទីជម្រក<br>សេវាសុខភាព<br>អប់រំ៖ កូនមិនបានចូលរៀន<br>ឯកសារបញ្ជាក់អត្តសញ្ញាណ<br>២-ការកេងប្រវ័ញ្ចនានា៖ កំលាំងពលកម្ម ផ្លូវភេទ អាពាហ៍ពិពាហ៍ដោយបង្ខំ ។ល។<br>៣-ខ្វះជំនាញ ភាសា ខ្វះការយល់ដឹងពីទំនៀមទម្លាប់ប្រពៃណី សាសនា | 1. No access to social services:<br>- Shelter/accommodation<br>- Health services<br>- Education: No schooling for children who migrate along with their parents<br>- Identity documents, in particular, for the baby born from migrants at their destination countries.<br>2. Exposed to exploitation: labour, sexual, forced marriage, etc.<br>3. Lack of skills, including languages, lack of aware of the tradition and culture of the own and hosting community. |
| ២. តើមានវិធានការអ្វីខ្លះ ដែលរាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានដោះស្រាយកន្លងមក រាប់ទាំងច្បាប់ គោលនយោបាយ យន្តការ និងការអនុវត្ត? | - រដ្ឋបាននិងកំពុងធ្វើឯកសារពាក់ព័ន្ធផ្តល់ភាពស្របច្បាប់<br>- មានច្បាប់ការងារ និងគោលនយោបាយទេសន្តប្រវេសន៍<br>- មានកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី នីតិវិធីប្រតិបត្តិបទដ្ឋាន<br>- បានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិ<br>- បានធ្វើសមាហរណកម្មពលករទៅសហគមន៍<br>- មានវគ្គបណ្តុះបណ្តាលតម្រង់ទិសមុនចេញដំណើរ | - State has been issuing relevant documents for migrants<br>- Labour Law and Migration Policy<br>- Bilateral and Multilateral Agreements, SOPs<br>- State has signed and ratified international legal instruments<br>- Assistance in reintegrating returned migrants into community<br>- Pre-Departure training. |
| ៣. តើច្បាប់ គោលនយោបាយ និងបទដ្ឋានជាតិ អន្តរជាតិពាក់ព័ន្ធទាំងនោះមានភាពប្រទាក់ក្រឡាគ្នាដូចម្តេច? | | |
| ៤. តើមានភាពប្រឈមអ្វីខ្លះក្នុងការអនុវត្តច្បាប់ ឬគោលនយោបាយទាំងនេះ ? | - ខ្វះឆន្ទៈ និងកិច្ចសហការពីដៃគូក្នុងការអនុវត្ត<br>- ខ្វះយន្តការផ្សព្វផ្សាយ ជំរុញ និងការតាមដានការអនុវត្ត<br>- ធនធានមនុស្ស និងថវិកា សម្ភារ ក្នុងការអនុវត្តនៅមានកម្រិត<br>- ការយល់ដឹង ការចូលរួមពីផ្នែកឯកជន និងសហគមន៍ នៅមានកម្រិត | - Lack of will and collaboration from partners in the implementation<br>- Lack of awareness raising mechanism, pushing and following up on the implementation<br>- Limited human resources, budget for the implementation<br>- Limited awareness and participation of private sectors and the community |

| | | |
|---|---|---|
| ៥. តើព្រះរាជាណាចក្រកម្ពុជាមានទិសដៅគ្រោងនឹង អនុវត្តក្នុងរយៈពេល ២ឆ្នាំ ៥ឆ្នាំ និង១០ឆ្នាំខាងមុខដូចម្ដេចខ្លះ?(ពិភាក្សាលើផែន ការដែលមានស្រាប់របស់រាជរដ្ឋាភិបាលឬតាមបណ្ដាក្រសួងស្ថាប័ន) | (មើលទៅលើផែនការសកម្មភាពនៃក្រុមការងារទាំង៦)<br>*ក្នុងប្រទេស៖*<br>- បន្តកែសម្រួល និងផ្តល់ភាពងាយស្រួលក្នុងការផ្តល់លិខិតធ្វើដំណើរដល់អ្នកចំណាកស្រុក<br>- គ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ<br>- ផ្សព្វផ្សាយពីឱកាសការងារក្នុងស្រុក ពីអត្ថប្រយោជន៍នានានៅក្នុងប្រទេស និងក្រៅប្រទេស<br>- បណ្តុះបណ្តាលតម្រង់ទិស និងកិច្ចការពារពីការជួញដូរមនុស្ស<br>*ក្រៅប្រទេស៖*<br>- បង្កើតអនុព័ន្ធការងារនៅប្រទេសដែលមានពលករកម្ពុជាចាប់ពី៥០០០នាក់ឡើងទៅ<br>- បើកផ្លូវឱ្យមានលទ្ធភាពបន្តធ្វើលិខិតផ្សេងៗ ដោយមិនចំបាច់ត្រឡប់មកកម្ពុជា ឬ បងប្អូនធ្វើជំនួសបាននៅក្នុងស្រុក | (Please see the action plan of the 6 working group of the NCCT)<br><br>*In-Country Goals*:<br>- Continue to revise and provide easiness in the passport application process for migrant workers.<br>- Manage Recruitment agencies<br>- Publicize local job opportunities and benefits of local and external jobs<br>- Provide orientations and protection from TIP<br><br>*Outside-Country Goals*:<br>- Create labour attache in the countries where there are 5,000 Cambodian migrant workers and more.<br>- Facilitate the issuance and renewal of relevant documents for migrant workers through the embassy, without having to return to obtain the documents, or having their relatives in Cambodia process the document on their behalf. |
| ៦. តើក្រសួង ស្ថាប័ន ទីភ្នាក់ ងារ ឬ អង្គភាពពាក់ព័ន្ធរបស់រដ្ឋណាខ្លះ ដែលកំពុងធ្វើការងារលើបញ្ហាទាំងនេះ? | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងទេសចរណ៍ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាអាជ្ញាកណ្តាល គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គណៈម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គណៈកម្មាធិការ COMMIT កម្ពុជា គណៈកម្មាធិការ SOMTC | - Ministry of Labour and Vocational Training<br>- Ministry of Interior<br>- Ministry of Social Affairs, Veterans and Youth Rehabilitation<br>- Ministry of Women's Affairs<br>- Ministry of Foreign Affairs and International Cooperation<br>- Ministry of National Defend<br>- Ministry of Education, Youth and Sports<br>- Ministry of Health<br>- Ministry of Information<br>- Ministry of Tourism<br>- Council of Ministers<br>- Ministry of Justice<br>- Cambodian Human Rights Committee<br>- NCCT<br>- COMMIT Cambodia<br>- SOM TC<br>- Council of Arbitration |
| ៧. តើតួអង្គអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាលសំខាន់ៗណាខ្លះ (មានដូច | IOM, UN-ACT, Win Rock, ILO, Ratanak International, CWCC, Chabdai, Licadho, ADHOC, សមាគម ACRA, សមាគមនិយោជក, | IOM, UN-ACT, Win Rock, ILO, Ratanak International, CWCC, Chab Dai, LICADHO, ADHOC, ACRA, Association of Employers, Asia Foundation, OHCHR, |

| | | |
|---|---|---|
| ជាអង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន គ្រឹះស្ថានអប់រំដែលអាចជាដៃគូជាដើម) សហប្រតិបត្តិការគ្នា ដើម្បីធ្វើការងារឆ្ពោះទៅរកគោលដៅនានាសម្រាប់បញ្ហានេះ? | ASIA Foundation, OHCHR, និយោជកក្នុង និងក្រៅប្រទេស | In-country and Out-country employers |
| ៨. តើមានអនុសាសន៍អ្វីខ្លះ សម្រាប់ប្រទេសនានា ដែលជាប្រទេសប្រភព ប្រទេសគោលដៅ និងប្រទេសសំចត អាចរួមគ្នាអនុវត្ត ដើម្បីលើកកម្ពស់សិទ្ធិ សុវត្ថិភាព និងផលប្រយោជន៍ប្រជាពលរដ្ឋដែលជាជនទេសន្តរប្រវេសន៍ និងគ្រួសាររបស់ពួកគេនៅទូទាំងពិភពលោក? | - ពន្លឿនការផ្តល់ភាពស្របច្បាប់ដល់ពលករទេសន្តរប្រវេសន៍និងក្រុមគ្រួសារ ដើម្បីពួកគាត់រស់នៅ និងធ្វើការប្រកបដោយសុវត្ថិភាព<br>- ប្រទេសបញ្ជូន និងប្រទេសទទួលផ្តល់វគ្គបណ្តុះបណ្តាលដល់ពលករឱ្យមានជំនាញច្បាស់លាស់មុន និងនៅពេលធ្វើការនៅក្រៅប្រទេស<br>- ពង្រឹង និងបង្កើតយន្តការតាមដានជាប្រចាំលើការគោរពសិទ្ធិមនុស្សនៅតាមកន្លែងការងារនៅប្រទេសទទួល<br>- សុំមានលក្ខខណ្ឌការងារពិសេសសម្រាប់ពលករលើទូកនេសាទសមុទ្រ និងការងារដែលងាយរងគ្រោះដទៃទៀត<br>- សុំផ្តល់ឯកសារផ្លូវច្បាប់នានានៃប្រទេសបញ្ជូន និងទទួល ដើម្បីផ្តល់ឧត្តមប្រយោជន៍ដល់ក្រុមគ្រួសារពលករចំណាកស្រុក និងកុមារ<br>- ប្រទេសទទួលផ្តល់សេវាសុខភាព និងអប់រំដល់កូនដែលទៅតាមឪពុកម្តាយ<br>- នៅពេលពលករនិងក្រុមគ្រួសារវិលមកប្រទេសដើមវិញ ប្រទេសបញ្ជូនត្រូវមានកម្មវិធីពិសេស ដើម្បីសមាហរណកម្មពួកគេ ទៅតាមសហគមន៍<br>- សុំកុំឱ្យនិយោជកដកហូតលិខិតឆ្លងដែនពីពលករ និងផ្តល់សិទ្ធិទំនាក់ទំនងក្នុងសង្គម<br>- សុំនិយោជកផ្តល់ឱកាសដល់ពលករបានរៀនសូត្រជំនាញ ភាសា ទំនៀមទម្លាប់ ប្រពៃណី សាសនា<br>- សុំឱ្យប្រទេសបញ្ជូន និងប្រទេសទទួលសហការសម្របសម្រួលផ្ទេររបបសន្តិសុខសង្គមរបស់ពលករ<br>- នៅពេលបញ្ជូនជនទេសន្តរប្រវេសន៍មកប្រទេសដើមវិញ ប្រទេសទទួលត្រូវគោរពគោលការណ៍សិទ្ធិមនុស្សជាសកល | - Accelerate the Provision of the regular status for migrants and their family to ensure their safe living and working<br>- Sending and receiving countries should provide pre-departure skill training and on-the job training to migrant workers<br>- Create and improve the regularly monitoring mechanisms on the human rights at workplace in the receiving countries<br>- There should be special/additional working conditions for migrant workers who are working in fishing industries and other industries that potentially pose vulnerability and danger to workers<br>- Legal documents should be issued in sending and receiving countries to ensure the best interests of the migrants' family and children<br>- The receiving countries should provide access to health and educational services to children who migrate along with their parents<br>- When migrants and their family return, the sending country should have special programs to reintegrate them into the community<br>- Employers should not keep the passport of the employees and should allow for social relationship with others<br>- Employers should allow their employees to have access to skill and language training and access to traditional, culture and religious exposure<br>- Sending and receiving countries should facilitate transfer of the Social Security Schemes<br>- When sending migrants back to their country or origin, universal human rights principles should be adhered to. |

## ទិស័យទី២ ៖ បំរែបំរួលអាកាសធាតុ និងគ្រោះធម្មជាតិ

ការឆ្លើយតបទៅនឹងកត្តាដែលនាំឲ្យមានទេសន្តរប្រវេសន៍ ដែលរាប់ទាំងកត្តាប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ កត្តាដែលបង្កដោយមនុស្ស ក្នុងនោះមាន ការបង្ការទប់ស្កាត់ កិច្ចការពារ ការផ្តល់ជំនួយសង្គ្រោះ ការដោះស្រាយវិបត្តិ វិធានការលុបបំបាត់ភាពក្រីក្រ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ល។

| | | |
|---|---|---|
| ១. តើបញ្ហាអ្វីខ្លះពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ ដែលចាំបាច់ត្រូវដោះស្រាយនៅក្នុងវិស័យដែលអ្នកបាន និងកំពុងពិភាក្សា? តើបញ្ហាទាំងនេះពាក់ព័ន្ធដូចម្តេចជាមួយកម្ពុជា ឬតំបន់? តើបញ្ហាណាខ្លះដែលជាអាទិភាពត្រូវលើកមកពិភាក្សា (៣ចំណុច)? | **ការយល់ដឹងកាន់តែប្រសើរអំពីបញ្ហាទេសន្តរប្រវេសន៍ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ**<br>- មិនមានយន្តការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលទាំងមូលដែលឆ្លុះបញ្ចាំងថា បញ្ហាទេសន្តរប្រវេសន៍គឺជាបាតុភូតមានហេតុ និងផលច្រើន និងមានច្រើនទិដ្ឋភាព<br>- ទទួលស្គាល់ផលប៉ះពាល់ខុសៗគ្នាអាស្រ័យទៅតាមកត្តាបរិបទ៖ សេដ្ឋកិច្ច សង្គម នយោបាយ បរិស្ថាន និងស្ថានភាពផ្ទាល់ខ្លួន រួមទាំងយេនឌ័រផងដែរ<br>- ការពារអ្នកដែលត្រូវផ្លាស់ទីដោយសារឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ និងការបំផ្លាញបរិស្ថាន ដូចជា បញ្ហាសុខភាព ជម្ងឺឆ្លង និងជម្ងឺផ្សេងៗ<br>- មិនមានឧបករណ៍ច្បាប់ជាក់លាក់ណាមួយគ្រប់គ្រងកិច្ចការពាររបស់ពួកគេឡើយ ។ ការបង្កើតដំណោះស្រាយច្បាប់ផ្អែក(ក្នុង និងក្រៅប្រទេស) ទៅលើការកំណត់រកឃើញនូវកាតព្វកិច្ចដែលទាក់ទងនឹង«សិទ្ធិ និងរដ្ឋ» របស់បុគ្គលដែលពាក់ព័ន្ធ<br>- ភាពខ្វះចន្លោះ ក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ឲ្យបានល្អនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងការបំផ្លាញបរិស្ថាន ជាពិសេសជនងាយរងគ្រោះ ដូចជាស្ត្រី កុមារ ជនចាស់ជរា និងជនងាយរងគ្រោះផ្សេងៗ<br>- សមត្ថភាពបន្សាំរបស់ថ្នាក់ជាតិមានកម្រិត៖ ក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយអាកាសធាតុ (ការលើកកម្ពស់ការយល់ដឹង ការទទួលបានព័ត៌មាន ប្រព័ន្ធផ្តល់ព័ត៌មានជាមុន កម្មវិធីឆ្លើយតបនឹងគ្រោះមហន្តរាយ ការត្រៀមបង្ការជាមុន/ផែនការត្រៀម...) ការវិនិយោគក្នុងការអន្តរាគមន៍លើការងារប្រែប្រួលអាកាសធាតុ ការផ្តល់នូវសកម្មភាពក្នុងការបង្កើននូវ | **Better Understanding of Migration, Environment and Climate Change**<br>- No mechanism for a whole of government approach reflecting that migration is a multi-causal and multidimensional phenomenon.<br>- Acknowledge the differentiated impacts depending on contextual factors: economic, social, political, environmental and personal circumstances including gender.<br>- Protection those displaced by the adverse effects of climate change and environmental degradation such as health issue, diseases and other illness.<br>- No single specific legal instrument governs their protection (Domestic or internationally). Development of legal solutions based on the identification of relevant individuals' rights and States' corresponding obligations.<br>- Gap in well-managed migration in the context of climate change and environmental degradation especially women, children, elderly people and other vulnerable people.<br>- Limitation of capacity at national level on adaptation: in response to disasters (raising awareness, accessing information, early warning system, emergency response and preparedness plan…), investment in intervention on climate change, increase more adaptation activities of the individual, community, private sectors and promote among migrant workers still limit.<br>- Problem at sending country: losing work forces, livelihood, increasing debt, drop out school for children, not accessing information which is hard to manage the community, vulnerability on the way of migration especially irregular migration. |

| | | |
|---|---|---|
| | ភាពធន់របស់សហគមន៍ មូលដ្ឋាន និងផ្នែកជំនួញ/ឯកជន និងការធ្វើការផ្សព្វផ្សាយពីទេសន្តរប្រវេសន្តនៅមានកម្រិត<br>- បញ្ហាក្នុងប្រទេសបញ្ជូនពលករ៖ បញ្ហាបាត់បង់នូវផលិតភាពការងារ ចិញ្ចឹមជីវិត កំណើននូវបំណុល បោះបង់ការសិក្សារបស់កុមារ មិនមានការផ្តល់ព័ត៌មានធ្វើឱ្យមានការស្មុគស្មាញក្នុងការគ្រប់គ្រងក្នុងសហគមន៍ទទួលរងគ្រោះក្នុងដំណើរការនៃការធ្វើចំណាកស្រុក និងចំណាកប្រទេសក្រៅប្រព័ន្ធ<br>- បញ្ហាប្រទេសទទួលពលករ៖ចំពោះពលករពលករទេសន្តរប្រវេសន្តមិនតាមប្រព័ន្ធ ជាពិសេសកុមារ និងស្ត្រីងាយរងគ្រោះ<br>- បញ្ហាផ្តល់ប័ណ្ណឆ្លងកាត់ព្រំដែន និងការគ្រប់គ្រងប័ណ្ណឆ្លងកាត់ព្រំដែន<br>- ការទទួលរងការធ្វើទារុណកម្មរបស់ពលករទេសន្តរប្រវេសន្តស្របច្បាប់<br>- កង្វះការអប់រំ និងទទួលបានព័ត៌មានពាក់ព័ន្ធនឹងការប្រើប្រាស់ទិដ្ឋាការ | - Problem at receiving country: for irregular migrants especially women and children are more vulnerable.<br>- Problem of providing border pass and way to manage this card.<br>- Some regular migrant workers were abused.<br>- Lacking education and accessing information of the use of VISA. |
| ២. តើមានវិធានការអ្វីខ្លះ ដែលរាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានដោះស្រាយកន្លងមក រាប់ទាំងច្បាប់ គោលនយោបាយ យន្តការ និងការអនុវត្ត? | - កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុដំណាក់កាលទី២ កម្មវិធីយុទ្ធសាស្ត្របញ្ច្រាបភាពធន់នឹងអាកាសធាតុ គម្រោងកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការរៀបចំផែនការ និងអនុវត្តសកម្មភាពអាទិភាព<br>- កម្មវិធីអភិវឌ្ឍន៍ក្រុងបៃតង<br>- រៀបចំឱ្យមានការធ្វើចំណាកស្រុកតាមប្រព័ន្ធ៖ ពេលវេលា ថវិកាចំណាយ ជានាឱ្យបាននូវការចាកចេញរបស់ទេសន្តរប្រវេសន្តបានប្រកបដោយសុវត្ថិភាព ឱ្យបានស្របតាមទិដ្ឋភាពផ្លូវច្បាប់ផ្សេងៗ<br>- យន្តការទ្វេភាគីរវាងប្រទេសបញ្ជូន និងប្រទេសទទួល។<br>- ការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារកម្ពុជា (២០១៤ - ២០១៨)<br>- ផ្សព្វផ្សាយច្បាប់ស្តីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម<br>- ផ្សព្វផ្សាយច្បាប់និងគោលនយោបាយស្តីពីការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម<br>- ការអនុវត្តអនុក្រិត្យ លេខ ១៩០ តាមរយៈការចេញសេចក្តីប្រកាសផ្សេងៗ | - Cambodia Climate Change Alliance (CCCA) Phase II<br>- Strategic Program for Climate Resilience<br>- Reducing the vulnerability of Cambodian rural livelihoods through enhanced sub-national climate change planning and execution of priority actions<br>- Green City Development Program<br>- Arrangement of the regular migration: times, budget, to ensure safely migrate of the migrant workers<br>- Bilateral mechanism between the sending and receiving countries<br>- Implementation of the labour migration policy of Cambodia (2014-2018)<br>- Promote the law on management of factory and handicraft<br>- Promote the law and policy on development of industry sector<br>- Implementation of the sub-degree 190 and their other prakas<br>- Food safety (implement GAP and monitor SPS)<br>- Intervention of emergency increasing efficiency of water resource through water saving system to help community |

| | | |
|---|---|---|
| | - សុវត្ថិភាពចំណីអាហារ(អនុវត្តGAP ចលនានាំចូលខុសច្បាប់ ការងារ SPS ពិនិត្យទីសត្តឃាត)<br>- ការប្រែប្រួលអាកាសធាតុ ពូជធន់អាកាសធាតុ ការធ្វើអន្តរាគមន៍សង្គ្រោះបន្ទាន់ បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកតាមរយៈកសាងប្រព័ន្ធសន្សំសំចៃទឹក ដើម្បីជួយដល់សហគមន៍<br>- ការពង្រីកលទ្ធភាពនៃការចិញ្ចឹមសត្វ និងត្រីនៅតាមសហគមន៍កសិកម្ម និងនេសាទ<br>- សកម្មភាពស្រាវជ្រាវកសិកម្ម គោលនយោបាយផ្សព្វផ្សាយកសិកម្ម<br>- ការអភិវឌ្ឍ និងអភិរក្ស(ព្រៃឈើ និងជលផល) | - Expanding animal feeding and fishery capacity at the agriculture and fishing community<br>- Agriculture activities and policy on promoting agriculture research<br>- The development and conservation (forest and fisheries) |
| ៣. តើច្បាប់ គោលនយោបាយ និងបទដ្ឋានជាតិ អន្តរជាតិពាក់ព័ន្ធទាំងនោះមានភាពប្រទាក់ក្រឡាគ្នាដូចម្តេច? | មានគោលនយោបាយ ផែនការយុទ្ធសាស្ត្រដោយឡែកៗ៖<br>- ផែនការយុទ្ធសាស្ត្រជាតិស្តីពីបម្រែបម្រួលអាកាសធាតុ (CCCSP) (2014-2023)<br>- ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង២០១៣ -២០៣០ (National Strategic plan on Green Growth2013-2030)<br>- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង (National Policy on Green Growth)<br>- គោលនយោបាយជាតិស្តីពីទេសន្តរប្រវេសន៍(2014-2018)<br>- គោលនយោបាយជាតិមុខរបរ (2014-2018)<br>- ច្បាប់ជាតិស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (2015)<br>- កិច្ចព្រមព្រៀង ASEAN ស្តីពីការឆ្លើយតបគ្រោះមហន្តរាយ និងសង្គ្រោះបន្ទាន់ (AADMER)<br>- ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (CCAP 2016-2020)<br>- ផែនការសកម្មភាពសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម(២០១៤-២០១៨)<br>- គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (២០១៥-២០២៥) | There are separately policies and strategic plans:<br>- Cambodia Climate Change Strategic Plan CCCSP (2014-2023)<br>- National Strategic plan on Green Growth (2013-2030)<br>- National Policy on Green Growth<br>- National Policy on Labour Migration (2014-2018)<br>- National Employment Policy (2014-2018)<br>- Cambodia Law on Disaster Management (2015)<br>- ASEAN Agreement on Disaster and Emergency Responses (AADMER)<br>- National Adaptation Programme of Action (NAPA)<br>- Sendai Framework for Disaster Risk Reduction (2015-2030) was adopted by UN Member States on 18 March 2015<br>- Action plan on response to climate change on each sector (CCAP 2016-2020)<br>- Action plan on risk reduction on disaster in agriculture sector (2014-2018)<br>- Policy on industry development in Cambodia (2015-2025)<br>- Promote and reinforce bilateral cooperation on regular crossing border without involvement of individual interest<br>- Sub-degree 190<br>- Law on disaster management 2015 |

| | | |
|---|---|---|
| | - លើកកម្ពស់ និងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីអំពីការឆ្លងដែនស្របច្បាប់ដោយមិនសំដៅផលប្រយោជន៍បុគ្គល<br>- អនុក្រិត្យ លេខ ១៩០<br>- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ២០១៥<br>- ក្របខណ្ឌHuygo សម្រាប់សកម្មភាព ២០០៥ ដល់២០១៥ ( Hyugo Framework for Action 2005-2015 )<br>- ក្របខណ្ឌសេនដាយ ស្តីពីការកាត់បន្ថយគ្រោះមហន្តរាយ Sendai ២០១៥ ដល់២០៣០( Framework for Disaster Risk Reduction 2015-2030 ) | - Huygo framework for action 2005-2015<br>- Framework for Disaster Risk Reduction 2015-2030 |
| ៤. តើមានភាពប្រឈមអ្វីខ្លះក្នុងការអនុវត្តច្បាប់ ឬគោលនយោបាយទាំងនេះ ? | - ធនធានដើម្បីធានាឲ្យមានការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្រ្តនៅថ្នាក់ជាតិ និងថ្នាក់តំបន់<br>- មិនមានក្រសួងបង្គោលដឹកនាំយុទ្ធសាស្រ្តចូលរួមចម្រុះពីខាងក្រសួងពាក់ព័ន្ធ<br>- ស្រ្តីនិងបុរសខ្វះការទទួលបានធនធានហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ទាប<br>- ខ្វះប្រព័ន្ធធារាសាស្រ្ត និង ប្រព័ន្ធធារាសាស្រ្តរងការខូចខាត<br>- ស្រ្តីនិងបុរសខ្វះការទទួលបានបច្ចេកទេស និងបច្ចេកវិទ្យាកសិកម្មដែលបន្សាំនឹងការ ប្រែប្រួលអាកាសធាតុ<br>- ស្រ្តីនិងបុរសខ្វះឱកាសការងារផ្សេង ក្រៅពីកសិកម្ម<br>- ខ្វះថវិកាក្នុងការអនុវត្តន៍គោលនយោបាយឱ្យមានប្រសិទ្ធិភាព<br>- ថ្វីត្បិតតែកម្ពុជាបានបង្កើតនូវយុទ្ធសាស្រ្ត និងក្របខ័ណ្ឌគោលនយោបាយជាច្រើន (ដែលគោលដៅបានកំណត់ទៅលើបញ្ហាជាអាទិភាព ឧទា.នៅក្នុងផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យបញ្ហាប្រឈមនាពេលបច្ចុប្បន្នគឺការឆ្ពោះទៅការ ( អនុវត្ត និងការជម្រុញការអនុវត្ត។<br>- បញ្ហាហិរញ្ញវត្ថុគឺជាផ្នែកមួយសំខាន់ ប៉ុន្តែការលើកកម្ពស់ការយល់ដឹង ការដឹកនាំ និងសមត្ថភាពក្នុងការអនុវត្តនិងពង្រឹងការអនុវត្ត ជាពិសេសនៅ | - Resources to ensure scientific national and regional level research is completed.<br>- No focal ministry leading a multi-ministry approach.<br>- Cross border initiatives require regional or bi-lateral agreements.<br>- Lacking in accessing the loan with low interest<br>- Lacking of irrigation system and some were damaged<br>- Lacking in technical and technology for agriculture which adapt to the climate change<br>- Lacking of job opportunity beside of agriculture<br>- Lacking of budget in implementing the policy for more efficiency<br>- Limitation of enforcement of the existing legal framework, policy, law, strategic plan to response to the climate change<br>- Limitation of capacity building activities and capacity in implementing at sub national level which require: system and behaviour change and time<br>- Debt increasing<br>- Lacking of data on loan management<br>- Lacking of monitoring<br>- Limitation of the capacity at the local level<br>- Limitation of information, sharing, reporting |

| | | |
|---|---|---|
| | ថ្នាក់ក្រោមជាតិ ទាមទារពេលវេលា៖ ការផ្លាស់ប្តូរប្រពន្ធ័ និងឥរិយាបថ គឺត្រូវការពេលវេលា<br>- បញ្ហាបំណុលកើន<br>- បញ្ហាការបញ្ចុះការប្រាក់<br>- បញ្ហាការបង្កើតទិន្នន័យដែលអាចគ្រប់គ្រងបានក្នុងការកម្ចីឥណទាន<br>- កង្វះការត្រួតពិនិត្យ<br>- ចំណេះដឹងនៅថ្នាក់មូលដ្ឋាននៅមានកម្រិត<br>- ការចែករំលែកព័ត៌មាន របាយការណ៍ គោលនយោបាយ មិនទាន់បានទូលំទូលាយ<br>- ជំនាញមិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារ | - Mismatch of skill and market needs |
| ៥. តើព្រះរាជាណាចក្រកម្ពុជាមានទិសដៅគ្រោងនឹង អនុវត្តក្នុងរយៈពេល ២ឆ្នាំ ៥ឆ្នាំ និង១០ឆ្នាំខាងមុខដូចម្តេចខ្លះ?(ពិភាក្សាលើផែន ការដែលមានស្រាប់របស់រាជរដ្ឋាភិបាលឬតាមបណ្តាក្រសួងស្ថាប័ន) | - បង្កើតភស្តុតាងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការបំផ្លាញបរិស្ថាន និងគ្រោះធម្មជាតិទៅលើទំនោរទេសន្តរប្រវេសន៍។<br>- បង្កើតយន្តការផ្លូវការក្នុងការធ្វើការពាក់ព័ន្ធនឹងវិស័យផ្សេងៗ។<br>- បញ្ចូលបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយ និងកិច្ចអន្តរាគមន៍។<br>- បង្កើនសមត្ថភាពស្ថាប័នថ្នាក់ជាតិ និងមូលដ្ឋាន និងអ្នកបង្កើតគោលនយោបាយក្នុងការឆ្លើយតបបញ្ហាប្រែប្រួលអាកាសធាតុ បរិស្ថាន និងទេសន្តរប្រវេសន៍។<br>- បង្កើតដំណោះស្រាយច្បាប់ដោយផ្អែកលើការកំណត់រកកាតព្វកិច្ចជាប់ទាក់ទង "សិទ្ធិ និងរដ្ឋ" របស់បុគ្គលពាក់ព័ន្ធ។<br>- បង្កើតគោលនយោបាយដែលឆ្លើយតបចំពោះវដ្តទាំងអស់នៃទេសន្តរប្រវេសន៍ជាមួយនឹងសកម្មភាពមុនពេល កំឡុងពេល និងក្រោយពេលធ្វើទេសន្តរប្រវេសន៍។<br>- សុវត្ថិភាពចំណីអាហារ(អនុវត្តGAP ចលនានាំចូលខុសច្បាប់ ការងារ SPS ពិនិត្យទីសត្តឃាត)<br>- ការប្រែប្រួលអាកាសធាតុ ពូជធន់អាកាសធាតុ ការធ្វើអន្តរាគមន៍សង្គ្រោះបន្ទាន់ បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកតាមរយៈកសាងប្រព័ន្ធសន្សំសំចៃទឹក ដើម្បីជួយដល់សហគមន៍ | - Develop evidence on the impacts of climate change, environmental degradation and natural disasters on migration trends.<br>- Develop formal mechanisms to work across thematic areas.<br>- Mainstream gender dimensions within policy and interventions.<br>- To enhanced capacity of national and local-level institutions and policymakers to address climate and environmental migration.<br>- Development of legal solutions based on the identification of relevant individuals' rights and States' corresponding obligations.<br>- Development of policies that address the whole migration cycle with activities before, during and after migration.<br>- Food safety (implement GAP and monitor SPS)<br>- Intervention of emergency increasing efficiency of water resource through water saving system to help community<br>- Expanding animal feeding and fishery capacity at the agriculture and fishing community<br>- Agriculture activities and policy on promoting agriculture research |

| | | |
|---|---|---|
| | - ការពង្រីកលទ្ធភាពនៃការប…មសត្វ និងត្រីនៅតាមសហគមន៍កសិកម្ម និងនេសាទ<br>- សកម្មភាពស្រាវជ្រាវកសិកម្ម គោលនយោបាយផ្សព្វផ្សាយកសិកម្ម<br>- ការអភិវឌ្ឍ និងអភិរក្ស(ព្រៃឈើ និងជលផល)<br>- ជំរុញលើកកម្ពស់ ពិនិត្យឡើងវិញ កែលម្អ តាមរយៈការចូលរួម ប្រឹក្សាយោបល់ ពីគ្រប់ភាគីពាក់ព័ន្ធ។<br>- ជាធម្មតា ផែនការយុទ្ធសាស្ត្រ សកម្មភាពអនុវត្តមិនទទួលបានជោគជ័យ ១០០ភាគរយនោះឡើយ អាស្រ័យហេតុនេះត្រូវតែមានការត្រួតពិនិត្យនិងវាយតម្លៃតាមបែបចូលរួម។ | - The …velopment and conservation (forest and fisheries)<br>- Require monitoring tools on the implementation of strategic plans<br>- Promote participation from relevant sector in reviewing, revising relevant policy. |
| ៦. តើក្រសួង ស្ថាប័ន ទីភ្នាក់ ងារ ឬ អង្គភាពពាក់ព័ន្ធរបស់រដ្ឋណាខ្លះ ដែលកំពុងធ្វើការងារលើបញ្ហាទាំងនេះ? | - អ្នកសម្របសម្រួលគោលនយោបាយពហុវិស័យ<br>- MoE, MAFF, MoWRAM, MOP, MOLVT, MOI, NCDM MAFF, NCDD, MIH, MoH, MoWA, MoEYS, MRD, | - A coordinator for multi sectors in policy development<br>- MoE, MAFF, MoWRAM, MOP, MOLVT, MOI, NCDM MAFF, NCDD, MIH, MoH, MoWA, MoEYS, MRD |
| ៧. តើតួអង្គអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាលសំខាន់ៗណាខ្លះ (មានដូចជាអង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន គ្រឹះស្ថានអប់រំដែលអាចជាដៃគូជាដើម) សហប្រតិ បត្តិការគ្នា ដើម្បីធ្វើការងារឆ្ពោះទៅរកគោលដៅនានាសម្រាប់បញ្ហានេះ? | - HRF, CHF, ADB, WB, FAO, EU, USAID, CDRI, UNDP, OM, Winrock, UN Act, WFP, HRF, UNDP, Action Aid, | - HRF, CHF, ADB, WB, FAO, EU, USAID, CDRI, UNDP, OM, Winrock, UN Act, WFP, HRF, UNDP, Action Aid, |
| ៨. តើមានអនុសាសន៍អ្វីខ្លះ សម្រាប់ប្រទេសនានា ដែលជាប្រទេសប្រភព ប្រទេសគោលដៅ និងប្រទេសសំចត អាចរួមគ្នាអនុវត្តដើម្បីលើកកម្ពស់សិទ្ធិ សុវត្ថិភាព | ធ្វើការឆ្លុះបញ្ចាំងភាពផ្សារភ្ជាប់គ្នានៅក្នុងក្របខណ្ឌគោលនយោបាយ និងច្បាប់៖<br>- ផ្អែកលើភស្តុតាង<br>- ការសម្របសម្រួលគោលនយោបាយឆ្លងវិស័យ (MOE, MAFF, MOP, MOLVT, MOI, NCDM) | Reflect the connections in policy and legal frameworks<br>- Evidence-based<br>- Cross-sectoral policy coordination (MOE, MOP, MOLVT, MOI, NCDM)<br>- Multi-disciplinary team capacity building activities to get involve from key government officials of the two different sectors (climate change & environment and migration) |

| | | |
|---|---|---|
